ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
**នាយកដ្ឋានព័ត៌មាន**

សេចក្តីប្រកាសព័ត៌មាន

# «លទ្ធផលសន្និបាតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោមមូលបទ «បង្កើនប្រសិទ្ធភាព ផលិតភាព និងគុណភាពការងារ»

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ ពីថ្ងៃទី ២៨-២៩ ខែមីនា ឆ្នាំ២០២៤ ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ចិន្តាសោភា** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង ប្រធានបេសកកម្មកម្ពុជានៅបរទេស និងតំណាងស្ថាប័នជាតិនានាជាភ្ញៀវកិត្តិយស។ អង្គសន្និបាតមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញផ្តល់អនុសាសន៍ និងការណែនាំប្រកបដោយគតិបណ្ឌិតនៅក្នុងពិធីបិទសន្និបាតក្រសួង នៅវិមានសន្តិភាព នារសៀលថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២៤។

## ១. លទ្ធផលការងារឆ្នាំ២០២៣

អង្គសន្និបាត បានធ្វើការកត់សម្គាល់ដោយការវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលសំខាន់ៗគួរជាទីមោទនៈដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០២៣ លើសមរភូមិការទូត ដោយផ្តោតជាចម្បងលើការងារធំៗ ចំនួន ៥ រួមមាន៖ (១) ការការពារផលប្រយោជន៍ជាតិ ការពារឯករាជ្យអធិបតេយ្យបូរណភាពទឹកដី (២) ការអនុវត្តគោលនយោបាយការបរទេសប្រកបដោយភាពបត់បែនវាងវៃតបទៅនឹងសម្ពាធភូមិសាស្ត្រនយោបាយ (៣) ការចូលរួមក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងដំណោះស្រាយបញ្ហាប្រឈមនានានៅក្នុងពិភពលោក (៤) ការអនុវត្តការងារការទូតសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ដើម្បីលើកស្ទួយសេដ្ឋកិច្ច និង (៥) ការបន្តការដ្ឋានកំណែទម្រង់ស្ថាប័ននៅក្នុងក្រសួង។ សមិទ្ធផលសំខាន់ៗ មានលម្អិតនៅក្នុងសេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលពិធីបើកសន្និបាតរបស់ក្រសួង។

## ២. ការងារកំណែទម្រង់ «បង្កើនប្រសិទ្ធភាព ផលិតភាព និងគុណភាពការងារ»

អង្គសន្និបាតបានដំណើរការកិច្ចប្រជុំចង្អៀតរយៈពេល១ថ្ងៃក្រោមមូលបទ៖ ការងារកំណែទម្រង់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ «បង្កើនប្រសិទ្ធភាព ផលិតភាព និងគុណភាពការងារ» ដែលក្នុងឱកាសនោះ ការពិភាក្សាបានផ្តោតទៅលើប្រធានបទសំខាន់ៗចំនួនពីរ៖

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

(១) ការងារកំណែទម្រង់ផ្ទៃក្នុងក្រសួង និង (២) ការងារកំណែទម្រង់ស្ថានតំណាងកម្ពុជានៅបរទេស។ នៅក្នុងការដឹកនាំកិច្ចពិភាក្សាចង្អៀត **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់អំពីកំណែទម្រង់ដោយផ្អែកលើអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី** ដែលបានលើកឡើងថា «**ការរៀបចំផ្ទះរបស់យើងជាកិច្ចការសំខាន់**» ដែលជាការអនុវត្តយ៉ាងត្រឹមត្រូវតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបន្តកំណត់យក «មនុស្ស» ជាអាទិភាពទី១ ក្នុងចំណោមអាទិភាពគន្លឹះទាំង៥ ដើម្បី «ជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងរក្សាចីរភាព»។ អំពីការងារចាំបាច់ដែលក្រសួងនឹងបន្តធ្វើនោះ គឺការបន្តកសាងសមត្ថភាព វិជ្ជាជីវៈ និងបណ្តុះបណ្តាល ធនធានមនុស្សក្នុងកិច្ចការការទូតនិងការបរទេស ដើម្បីឱ្យមន្ត្រីការទូតរបស់កម្ពុជាកាន់តែមានមនសិការជាតិ មានសមត្ថភាពខ្ពស់ ជំនាញថ្មីគ្រប់គ្រាន់ មានភាពប៉ិនប្រសប់ និងជាយុទ្ធជនឈានមុខក្នុងការការពារផលប្រយោជន៍ជាតិ និងប្រជាជន។

ចំពោះរបៀបរបបការងារ និងរំហូរឯកសារ អង្គសន្និបាតបានគាំទ្រគំនិតផ្តួចផ្តើមរបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក្នុងការបង្កើត Portal ដើម្បីឱ្យការបញ្ជូន និងតាមដានឯកសារឱ្យមានភាពឆាប់រហ័ស ដែលជាជំហានឆ្ពោះទៅរក E-Government។ ក្នុងអាណត្តិរាជរដ្ឋាភិបាលថ្មី **សម្តេចធិបតី** បានដាក់ចេញជាគោលការណ៍ការកែទម្រង់រដ្ឋបាលសាធារណៈ គឺ "ការរៀបចំផ្ទះជាមុនសិន" ដែលឆ្នាំ២០២៤នេះ មិនអនុញ្ញាតឱ្យមានការជ្រើសរើសមន្ត្រីថ្មី ប៉ុន្តែត្រូវរៀបចំប្រើប្រាស់មន្ត្រីដែលមានស្រាប់ឱ្យចំគោលដៅ និងអស់លទ្ធភាព តាមរយៈការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រី។

ចំពោះការងារធនធានមនុស្ស អង្គសន្និបាតបានពិភាក្សាយ៉ាងស៊ីជម្រៅ អំពីលទ្ធផលនៃការបំពេញការងារនិងការអនុវត្តការងាររបស់មន្ត្រីការទូត និងរិះរកមធ្យោបាយនានាក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយ ដើម្បីបង្កើនប្រសិទ្ធភាពនៃកំណែទម្រង់ទៅអនាគត។ ការគិតគូរ ការរៀបចំចងក្រង និងការអនុវត្តគោលនយោបាយការបរទេសប្រកបដោយភាពត្រឹមត្រូវ ម៉ត់ចត់ ថ្លឹងថ្លែង បត់បែន និងគ្រប់ជ្រុងជ្រោយ អាចប្រព្រឹត្តទៅបាន លុះត្រាណាតែមន្ត្រីរបស់យើងសកម្ម មានវិជ្ជាជីវៈ មានសមត្ថភាព និងមានមនសិការជាតិ រួមទាំងមានការគាំទ្រផ្នែកសម្ភារៈ ហេដ្ឋារចនាសម្ព័ន្ធ និងស្មារតី ជាពិសេសដល់ការអនុវត្តការងារប្រចាំថ្ងៃ។

អង្គសន្និបាតបានជំរុញឱ្យវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ដើរតួនាទីកាន់តែសកម្ម ក្នុងការងារបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឱ្យមន្ត្រីការទូតយើងមានសមត្ថភាព និងជំនាញវិជ្ជាជីវៈកាន់តែមុតស្រួច។ ការបន្តអភិវឌ្ឍសមត្ថភាពការងារផ្សារភ្ជាប់នឹងគុណភាពបណ្តុះបណ្តាល គឺដើម្បីធានាដល់និរន្តរភាព ស្របតាមតម្រូវការតាមអង្គភាពនីមួយៗក្រោមឱវាទក្រសួង។ ក្នុងបរិបទនៃបដិវត្តឧស្សាហកម្មទី៤ និងបរិវត្តន៍ ឌីជីថល មន្ត្រីការទូតរបស់យើងក៏ត្រូវផ្សារភ្ជាប់ជាមួយជំនាញឌីជីថល និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងគោលដៅពង្រឹងសុវត្ថិភាពទិន្នន័យលើប្រព័ន្ធកុំព្យូទ័រ បង្កើនប្រសិទ្ធភាព និងគុណភាពការងារ។ ជាងនេះទៀតការរៀបចំប្រព័ន្ធឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន នៅផ្ទៃក្នុងក្រសួង និងនៅតាមស្ថានតំណាងកម្ពុជានៅបរទេស ក៏ស្ថិតក្នុងអាទិភាពបន្តនៃកំណែទម្រង់របស់ក្រសួង ហើយដែលទាំងនេះតម្រូវឱ្យមានប្រភពធនធានបន្ថែមទាំងផ្នែកហិរញ្ញវត្ថុ និងមន្ត្រីបច្ចេកទេស។

## ៣. ការបូកសរុបសន្និបាត

ក្នុងរបាយការណ៍គោរពជូន **សម្តេចធិបតី** ដែលបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធីបិទសន្និបាតនៅរសៀលថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា** បានគូសបញ្ជាក់ជាអាទិ៍ថា៖

- ការខិតខំយកចិត្តទុកដាក់ចូលរួមចំណែកក្នុងកិច្ចការពារអធិបតេយ្យភាព និងបូរណភាពទឹកដី តាមរយៈការថែរក្សា និងលើកកម្ពស់បរិយាកាសអំណោយផល និងចូលរួមចំណែកជំរុញការងារកំណត់ខណ្ឌសីមាព្រំដែន និងបោះបង្គោលព្រំដែនដែលនៅសេសសល់ឱ្យបានចប់ឆាប់។
- ក្រសួងបានបន្តខិតខំការពារ និងលើកតម្កើងកិត្តិនាម និងកិត្តិយសរបស់កម្ពុជា និងសេចក្តីថ្លៃថ្នូររបស់ជាតិ តាមរយៈការចូលរួមយ៉ាងសកម្មក្នុងការបកស្រាយបំភ្លឺ ការចែករំលែកព័ត៌មាន និងការផ្សព្វផ្សាយអំពីស្ថានភាពជាក់ស្តែងនៅកម្ពុជា ដើម្បីប្រឆាំង និងទប់ស្កាត់ការបំភ្លៃការពិត ការចោទប្រកាន់ដោយគ្មានមូលដ្ឋាន និងការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជា នៅក្នុងគ្រប់វេទិកាតំបន់ និងអន្តរជាតិ ជាពិសេសនៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការ សហប្រជាជាតិ ជាច្រើនលើក។
- ក្រសួងបានដើរតួយ៉ាងសំខាន់ក្នុងការជួយសង្គ្រោះ និងការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ដែលរងគ្រោះពីការរំលោភសិទ្ធិ អំពើហិង្សា និងការជួញដូរនៅក្រៅប្រទេស។
- ទំនាក់ទំនងការទូតរវាងកម្ពុជាជាមួយបណ្តាប្រទេសនៅអឺរ៉ុបមានការកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសតាមរយៈព្រះរាជទស្សនកិច្ចរបស់ **ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** នៅប្រទេសបារាំង និងទស្សនកិច្ចផ្លូវការរបស់ប្រធានាធិបតីអាល្លឺម៉ង់ នៅកម្ពុជា។
- នៅឆ្នាំ២០២៣ សកម្មភាពការងារការទូតរបស់កម្ពុជា បានពង្រីកដល់តំបន់អាមេរិកកណ្តាល ការ៉ាបៀន អាមេរិកខាងត្បូង រហូតទៅដល់តំបន់អាហ្វ្រិកខាងជើង និងមជ្ឈិមបូព៌ា។
- ក្នុងក្របខ័ណ្ឌពហុភាគី កម្ពុជាក៏បានបន្តចូលរួមយ៉ាងសកម្មក្នុងយន្តការពហុភាគីជាច្រើន ដើម្បីចូលរួមក្នុងការកសាងសហគមន៍ នៅក្នុងតំបន់ និងសកលលោក ប្រកបដោយសន្តិភាព សន្តិសុខ និងវិបុលភាព។
- ក្នុងក្របខ័ណ្ឌអាស៊ាន កម្ពុជាបានចូលរួមយ៉ាងសកម្ម ក្នុងការរក្សាមជ្ឈភាពអាស៊ាន ដែលជាតម្លៃយុទ្ធសាស្ត្រសម្រាប់អាស៊ាន ក្នុងទំនាក់ទំនងជាមួយដៃគូទាំងអស់។
- កម្ពុជាបានប្តេជ្ញាចូលរួមយ៉ាងសកម្មក្នុងក្របខ័ណ្ឌនានា ដូចជា មេគង្គ និងអេកម៉ិក ក្នុងគោលបំណងរួមចំណែកអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច នៅក្នុងអនុតំបន់ ដែលក្នុងនោះកម្ពុជាបានទទួលអត្ថប្រយោជន៍ពីមូលនិធិពិសេសមេគង្គ-ឡានឆាង។

- កម្ពុជាបានបន្តរួមចំណែកលើកស្ទួយសន្តិភាព តាមរយៈការចូលរួមក្នុងប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដោយការបញ្ជូនកងកម្លាំងរក្សាសន្តិភាពក្រោមឆ័ត្រអង្គការសហប្រជាជាតិ។
- ក្នុងឆ្នាំ២០២៣ ក្រសួងបានបន្តជំរុញការងារការទូតសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍។
- ក្រសួងបានខិតខំអនុវត្តតាមខ្លឹមសារដូចដែលមានចែងក្នុងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈជាមូលដ្ឋានក្នុងកិច្ចការកែទម្រង់ស្ថាប័នបន្តិចម្តងៗ និងបន្តផ្តោតលើការពង្រឹងការគ្រប់គ្រងធនធានមនុស្ស ការងាររដ្ឋបាល ការកែលម្អកិច្ចការហិរញ្ញវត្ថុ និងការលើកទឹកចិត្ត មន្ត្រីរាជការ ដើម្បីបង្កើនប្រសិទ្ធភាព ផលិតភាព និងគុណភាពការងារ ដែលជាបច្ច័យវិជ្ជមានដល់ការលើកកម្ពស់ផលប្រយោជន៍និងកិត្យានុភាពជាតិ។

## ៤. អនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចធិបតីនាយករដ្ឋមន្ត្រី

ថ្លែងក្នុងពិធីបិទសន្និបាត **សម្តេចធិបតី** បានអបអរសាទរ និងកោតសរសើរចំពោះសមិទ្ធផលដែលក្រសួងការបរទេសសម្រេចបានក្នុងឆ្នាំ២០២៣ និងបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួង។ **សម្តេចធិបតី** បានផ្តល់អនុសាសន៍ និងការវិភាគដ៏ស៊ីជម្រៅលើបញ្ហាប្រឈមនានាដែលសកលលោកកំពុងជួបប្រទះ និងផលបច្ច័យនៃភាពតានតឹងភូមិសាស្ត្រនយោបាយ ព្រមទាំងផ្តល់គោលការណ៍ណែនាំដ៏ខ្ពង់ខ្ពស់ និងទិសដៅគោលនយោបាយ សំដៅរក្សាផលប្រយោជន៍ស្នូលរបស់កម្ពុជា ដូចខាងក្រោម៖

- ត្រូវពឹងផ្អែកទៅលើឧបករណ៍សំខាន់ពីរ យ៉ាងតិច ដើម្បីសម្រេចការងាររបស់ខ្លួន រួមមាន៖ (១) ការវិភាគយុទ្ធសាស្ត្រ និង (២) ការធ្វើផែនការយុទ្ធសាស្ត្រការទូត។
- លើកទឹកចិត្តឱ្យក្រសួងរៀបចំ ***"សៀវភៅស្តីពីគោលនយោបាយការបរទេស"*** សម្រាប់ជាបន្ទាត់ក្នុងការអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។
- ត្រូវពង្រឹងបន្ថែមនូវការលើកកម្ពស់ការងារការទូតសេដ្ឋកិច្ច និងវប្បធម៌ឱ្យកាន់តែទូលំទូលាយ សំដៅទាក់ទាញការវិនិយោគ ពង្រីកទីផ្សារសម្រាប់ផលិតផលជាតិ ផ្សព្វផ្សាយសក្តានុពលទេសចរណ៍ និងបង្ហាញភាពសម្បូរបែបនៃវប្បធម៌និងអរិយធម៌ដ៏រុងរឿងរបស់កម្ពុជា។
- ត្រូវបន្តលើកទឹកចិត្ត ដោយផ្អែកលើគោលការណ៍គុណាធិបតេយ្យ សមិទ្ធផលនិងប្រសិទ្ធភាពការងារ វិន័យ និងការប្តេជ្ញាបំពេញការងាររបស់មន្ត្រី។
- កម្ពុជាប្រកាន់ជំហរធ្វើជាមិត្តជាមួយគ្រប់គ្នា និងមិនធ្វើសត្រូវជាមួយនរណាម្នាក់ដោយមិនធ្វើការជ្រើសរើសរវាងភាគីណាមួយឡើយ។
- ត្រូវអនុវត្តនយោបាយការបរទេសកាន់តែមានភាពបុរេសកម្ម បត់បែន ថ្លឹងថ្លែង និងឈ្លាសវៃបំផុត ដោយប្រកាន់យកនូវជំហរអព្យាក្រឹត្យអចិន្ត្រៃយ៍ ឯករាជ្យ និងផ្អែកលើច្បាប់ នៅក្នុងទំនាក់ទំនងជាមួយដៃគូទាំងអស់ ដើម្បីធានាថា អធិបតេយ្យភាព ឯក

រាជ្យភាព អព្យាក្រឹតភាព សេចក្តីថ្លៃថ្នូរ និងវិបុលភាពរបស់ជាតិយើង ត្រូវបានការពារ និងលើកកម្ពស់បន្ថែមទៀត ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។

- ត្រូវប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់ និងតម្កល់ផលប្រយោជន៍ស្នូលរបស់ជាតិ និងប្រជាជន ជាធំ។
- បន្តជំរុញសកលភាវូបនីយកម្ម និងកិច្ចសហប្រតិបត្តិការពហុភាគីនិយម ដែលបើកចំហ សេរី តម្លាភាព យុត្តិធម៌ បរិយាបន្ន និងផ្អែកលើច្បាប់អន្តរជាតិ ដោយមិនគាំទ្រសកម្មភាពទាំងឡាយណាដែលមានចរិតលក្ខណៈគាំពារនិយម និងឯកតោភាគីនិយម។
- ត្រូវបន្តប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ទាំងឡាយដែល មានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ធម្មនុញ្ញអាស៊ាន និងបទដ្ឋានដែលទទួលស្គាល់ជាសាកលផ្អែកលើការគោរពគ្នាទៅវិញទៅមកចំពោះឯករាជ្យភាព អធិបតេយ្យភាព សមភាព បូរណភាពទឹកដី អត្តសញ្ញាណជាតិ និងសិទ្ធិដឹកនាំអត្តិភាពជាតិ ដោយមិនមានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ការធ្វើវិទ្ធង្សនា ឬការបង្ខិតបង្ខំ និងការដំណោះស្រាយជម្លោះដោយសន្តិវិធី។

នៅចុងបញ្ចប់នៃកម្មវិធីបិទ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក៏បានផ្តល់កិត្តិយសបំពាក់មេដាយ និងគ្រឿងឥស្សរិយយសដល់មន្ត្រីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមួយចំនួន ផងដែរ។

គួរកត់សម្គាល់ថា នៅមុនការប្រព្រឹត្តទៅនៃសន្និបាត នៅថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ ២០២៤ ក្រសួងក៏បានរៀបចំសិក្ខាសាលាស្តីពី «ការគ្រប់គ្រងវិបត្តិផ្នែកការទូតៈ ទ្រឹស្តីរួម និងការអនុវត្តជាក់ស្តែង» សម្រាប់ថ្នាក់ដឹកនាំ ឯកអគ្គរាជទូត និងអគ្គកុងស៊ុលកម្ពុជា និង «កិច្ចប្រជុំបូកសរុបសមិទ្ធផលរយៈពេល៣ឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច និងប្រមូលធាតុចូលសម្រាប់ការរៀបចំយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២៤-២០២៨»។ សិក្ខាសាលានេះ បានផ្តល់ជូនមន្ត្រីការទូតជាន់ខ្ពស់កម្ពុជា នូវការយល់ដឹងតែទូលំទូលាយអំពីបញ្ហានៃការគ្រប់គ្រងវិបត្តិ បង្កើនទំនុកចិត្តនៃការធ្វើសេចក្តីសម្រេចចិត្ត ការធ្វើទំនាក់ទំនង និងជំនាញភាពជាអ្នកដឹកនាំលើការគ្រប់គ្រងស្ថានភាពមានវិបត្តិនានា ដើម្បីការពារអត្ថប្រយោជន៍ប្រជាពលរដ្ឋ និងប្រទេសកម្ពុជាលើឆាកអន្តរជាតិ។ រីឯ កិច្ចប្រជុំបូកសរុបសមិទ្ធផលរយៈពេល ៣ឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច បានទទួលនូវធាតុចូលសំខាន់ៗ ជាច្រើនពីភាគីពាក់ព័ន្ធ សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការរៀបចំយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២៤-២០២៨ ឱ្យស្របជាមួយនឹងបរិបទថ្មី នៃរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៧ ដែលយុទ្ធសាស្ត្រនេះនឹងជួយតម្រង់ទិស អ្នកការទូតកម្ពុជា ក្នុងបេសកកម្មការពារ និងបង្កើនផលប្រយោជន៍កម្ពុជា នៅលើឆាកអន្តរជាតិ ពិសេសនឹងចូលរួមចំណែកសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០៥០។

ថ្ងៃសុក្រ ៥រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២៤